# ចៃម្សៅ / Mealybug

*Ferrisia virgate*












## ១. លក្ខណៈទូទៅ

ក្នុងអំឡុងពីខែមិថុនា ទៅខែកក្កដា ម្រេចចាប់ផ្តើមលាស់ត្រួយ ហើយបន្ទាប់មកវាចេញផ្កា និងបង្កើតក្ួរ វាជាដំណាក់កាលអំណោយផលដល់ការកើតមានចៃម្សៅ បើសិនជាមានការរាំងស្ងួតមួយរយៈ ក្នុងនោះកូនតូចៗ និងមេចំណាស់របស់ចៃម្សៅនឹងធ្វើការជញ្ជក់រុក្ខរសពីពន្លក ស្លឹកខ្ចីៗ និងផ្លែ ដែលបណ្តាលឱ្យបន្ថយការលូតលាស់របស់ដើមម្រេច។

ចៃម្សៅជាច្រើន នឹងធ្វើការភ្ជាប់ខ្លួនទៅនឹងឫសនៃដើម រួចហើយក៏បឺតយករុក្ខរស ដែលធ្វើឲ្យដើមដំណាំប្រែទៅជាពណ៌លឿង ស្លឹក និងធាងក្រៀម ហើយក៏ជ្រុះ។ ដើមម្រេចជាច្រើនដែលរងការបំផ្លាញពីចៃម្សៅលើឫស គឺមាន លក្ខណៈដូចការបំផ្លាញពីពពួកផ្សិត *Phytophthora sp.* និងណែម៉ាតូតដែរ។

| មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | |

In the printed chart, the cells under កក្កដា, វិច្ឆិកា and ធ្នូ are red; all the other cells are light grey.

■ (red) មានការបំផ្លាញច្រើន □ (light grey) មានវត្តមាន

## ២. វដ្តជីវិត

ចៃម្សៅមានវដ្តជីវិតពេញលេញ រយៈពេលប្រហែល ៣០ថ្ងៃ ដោយមិនមានជីវិតក្រាំងឡើយ។ សត្វញីធ្វើការទំលាក់ពងដែលមានពណ៌លឿងខ្ចី ឬទឹកក្រូច។ ដំណាក់កាលដង្កូវរបស់វាមានរយៈពេល ១៩ថ្ងៃ(សត្វឈ្មោល) និង ២១ថ្ងៃ(សត្វញី)។ សត្វពេញវ័យ(ញី)មានពណ៌ផ្កាឈូកខ្ចី ដែលគ្របដោយម្សៅពណ៌ស ចំពោះការបំផ្លាញវិញសត្វញីមានការបំផ្លាញយ៉ាងធ្ងន់ធ្ងរនៅក្នុងចំការ គេកម្រប្រទះឃើញសត្វឈ្មោលណាស់។

រៀបចំដោយ៖ នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម
ឧបត្ថម្ភដោយ៖ គម្រោងជំរុញសុវត្ថិភាពចំណីអាហារ ខ្សែច្រវាក់តម្លៃដំណាំម្រេច និងការបើកទីផ្សារក្នុងប្រទេសវៀតណាម ឡាវ និងកម្ពុជា (STDF/PG/619)

## ៣. ការអង្កេតតាមដាន



ជាទូទៅវត្តមានរបស់ស្រមោច (ស្រមោចខ្មៅ ក្រហម ឬស្រមោចជើងវែង) នៅលើដើមម្រេច គឺជាសញ្ញាប្រាប់ថាមានវត្តមានចៃម្សៅនៅក្នុងចម្ការហើយ ដោយសារចៃម្សៅនេះបញ្ចេញទឹកដមមានជាតិស្ករ ដែលស្រមោចចូលចិត្ត។ ចៃម្សៅកើតមាននៅលើពន្លក លើត្រួយខ្ចីៗ និងលើកួរ ប៉ុន្តែនៅពេលមានការបំផ្លាញខ្លាំង ចៃម្សៅក៏មាននៅលើស្លឹក លើទង និងកួរម្រេចចាស់ៗដែរ។







## ៤. វិធានការគ្រប់គ្រង និងកម្ចាត់

- ថែរក្សាពពួកសត្វល្អិតមានប្រយោជន៍ដែលស៊ីចៃម្សៅ ដូចជាសត្វស្រមោច អង្រ្កង អណ្តើកមាស ឱម៉ាល ជាដើម។
- ធ្វើការត្រួតពិនិត្យជាប្រចាំ និងដោយយកចិត្តទុកដាក់ អំពីវត្តមានរបស់ចៃម្សៅ នៅក្នុងរដូវដែលមានការបំផ្លាញខ្លាំង ហើយការសង្កេតគួរធ្វើនៅពេលព្រឹកព្រលឹម។
- កាត់មែកដែលនៅជិតគល់ និងដីចេញ ដើម្បអនាម័យចម្ការ
- បន្ទាប់ពីប្រមូលផលរួច ត្រូវធ្វើអនាម័យចម្ការ និងបង្កើន pH របស់ដីជាមួយម្សៅកំបោរ។ ប្រើ ១ ០០០ គីឡូក្រាម/ហិកតា ចែកជា ២ ដំណាក់កាលម្តង ប្រើ ៥០០គីឡូក្រាម មិនត្រូវបាចផ្ទាល់ទៅលើគល់តែម្តងទេ ត្រូវដាក់ចូលតាមប្រព័ន្ធស្រោចស្រព ដើម្បីសម្លាប់ប្រភពមេរោគ។
- ប្រើថ្នាំពុលផ្សំពីរុក្ខជាតិ មានថ្នាំជក់(ខ្លាំង) ២-៥គីឡូក្រាម មើមក្តួច ៣-៥គីឡូក្រាម និងល្ងាសៀម ២-៥គីឡូក្រាម ដោយត្រាំជាមួយទឹក ៦០លីត្ររយៈពេល៥-១០ថ្ងៃ ទើបយកទៅបាញ់លើចៃម្សៅ។
- បាញ់ថ្នាំសម្លាប់សត្វល្អិត នៅពេលមានការបំផ្លាញខ្លាំង និងការបាញ់ថ្នាំពុលផ្សំពីរុក្ខជាតិមិនមានប្រសិទ្ធភាព។ ប្រើថ្នាំប៊ុយប្រូហ្វេស៊ីន (Buprofezin) ឈ្មោះលក់នៅលើទីផ្សារ ប៊ុយទីល (Butyl 10WP) ឬអាប់ផ្លូដ (Applaud 10WP) ដោយបាញ់ក្នុងកម្រិត ២០ក្រាម លាយទឹក ៨លីត្រ ឆ្លាស់គ្នាជាមួយថ្នាំ អាសេតាមេព្រីត (Acetamiprid) ឈ្មោះលក់លើទីផ្សារ អាស់សិនដ៍ (Ascend 20SP) ដោយបាញ់ក្នុងកម្រិត ៥-១០ក្រាម លាយទឹក ៨លីត្រ ឬប្រើថ្នាំ ឌីណូតេហ្វុយរ៉ាន (Dinotefuran) ឈ្មោះលក់លើទីផ្សារ អូស៊ីន (OSHIN 20WP) ក្នុងកម្រិត ៦,៥ក្រាម លាយទឹក ១៦លីត្រ។ គេអាចធ្វើការប្រមូលយ៉ាងហោចណាស់ ក្រោយពីធ្វើការបាញ់ថ្នាំបាន ៧ថ្ងៃ ចំពោះថ្នាំដែលបានណែនាំឱ្យប្រើប្រាស់ខាងលើ។ ធ្វើការបាញ់ថ្នាំនៅពេលគ្មានភ្លៀង ហើយបាញ់នៅពេលព្រឹក ឬល្ងាច។

*ចំណាំ៖ ១. ជៀសវាងការបាញ់ថ្នាំកំឡុងពេលជិតប្រមូលផល*
*២. រាល់ការប្រើប្រាស់ថ្នាំកសិកម្ម ត្រូវអនុវត្តតាមការណែនាំនៅលើស្លាកសញ្ញាព័ត៌មានរបស់ថ្នាំកសិកម្ម*
*៣. ជៀសវាងការបង្កើនភាពស៊ាំរបស់សត្វល្អិតទៅនឹងថ្នាំកសិកម្ម ត្រូវប្រើប្រាស់ ឬ ផ្លាស់ប្តូរថ្នាំកសិកម្ម*

រៀបចំដោយ៖ នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម
ឧបត្ថម្ភដោយ៖ គម្រោងជំរុញសុវត្ថិភាពចំណីអាហារ ខ្សែច្រវាក់តម្លៃដំណាំម្រេច និងការបើកទីផ្សារក្នុងប្រទេសវៀតណាម ឡាវ និងកម្ពុជា (STDF/PG/619)